**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

**មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍**
**សើស្បែកនិងកាមរោគ**

## របាយការណ៍ស្តីពី
## សកម្មភាពការអប់រំផ្សព្វផ្សាយ និងធ្វើតេស្តឈាមរកមេរោគអេដស៍ ថ្ងៃទី ១ ក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក របស់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
**សម្រាប់សកម្មភាពថ្ងៃទី១៖ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៤**

ដោយទទួលបានការណែនាំ និងចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមសាស្ត្រាចារ្យ ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រោមការដឹកនាំដោយផ្ទាល់ដោយ **ឯកឧត្តមវេជ្ជបណ្ឌិត ស៊ឹម ស៊ុំយេង** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល **ឯកឧត្តមវេជ្ជបណ្ឌិត មាន ឈីវុន** ទីប្រឹក្សាក្រសួងសុខាភិបាល និង **លោកសាស្ត្រាចារ្យជំនួយ អ៊ុក វិជ្ជា** ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ នារសៀលថ្ងៃពុធ ១៣កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៤ ត្រូវនឹងថ្ងៃទី១នៃយុទ្ធនាការក្រុមការងារមជ្ឈមណ្ឌលជាតិ និងអង្គការដៃគូពាក់ព័ន្ធបានរៀបចំយុទ្ធនាការផ្សព្វផ្សាយអប់រំការយល់ដឹងស្តីពីការបង្ការមេរោគអេដស៍និងជំងឺអេដស៍ និងចុះចែកស្រោមអនាម័យដោយឥតគិតថ្លៃដល់កីឡាករអុំទូក និងដល់សាធារណជនដែលចូលរួមនៅក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក នៅតំបន់ទីក្រុងរណបជ្រោយចង្វារ (OCIC) ដែលចាប់ផ្តើមដោយមានការហែរដើរក្បួនដែលដឹកនាំដោយ **ឯកឧត្តមវេជ្ជបណ្ឌិត ស៊ឹម ស៊ុំយេង** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល **ឯកឧត្តម វេជ្ជបណ្ឌិត មាន ឈីវុន** ទីប្រឹក្សាក្រសួងសុខាភិបាល និង **លោកសាស្ត្រាចារ្យជំនួយ អ៊ុក វិជ្ជា** ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដែលមានកាន់បដា និងរូបភាពផ្សព្វផ្សាយទាក់ទាញផ្សេងៗ ស្រោមអនាម័យ ព្រមទាំងមានការចូលរួមផងពីសំណាក់ ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ តំណាងមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ អង្គការដៃគូរួមមានអង្គការ AHF, FHI 360, KHANA, PSI, MHC, CWPD និងសមាគមឈូកស សរុបចំនួន ១២០ នាក់។

ឆ្លៀតក្នុងឱកាសយុទ្ធនាការនោះផងដែរ **ឯកឧត្តមសាស្ត្រាចារ្យ ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល រួមជាមួយថ្នាក់ដឹកនាំក្រសួងសុខាភិបាល បានអញ្ជើញចុះពិនិត្យការរៀបចំទីតាំងជម្រកតង់សុខភាពក្រុមគ្រូពេទ្យ

យាមប្រចាំការ និងរថយន្តគិលានសង្គ្រោះនៅតាមបណ្តាគោលដៅនីមួយៗ ដើម្បីចូលរួមការពារ ពិនិត្យព្យាបាលសុខភាពជូនប្រជាពលរដ្ឋ ដែលអញ្ជើញមកចូលរួមទស្សនា ក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក និងស្តង់ផ្សព្វផ្សាយអប់រំការយល់ដឹងស្តីពីការបង្ការមេរោគអេដស៍និងជំងឺអេដស៍របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។





តាមផែនការគ្រោងទុក ក្រសួងសុខាភិបាល មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងអង្គការដៃគូពាក់ព័ន្ធបានត្រៀមសម្ភារ បរិក្ខារ និងខិត្តប័ណ្ណអប់រំផ្សព្វផ្សាយសម្រាប់សកម្មភាពនៃការអប់រំផ្សព្វផ្សាយពី

មេរោគអេដស៍ និងជំងឺអេដស៍ក្នុងព្រឹត្តិការណ៍នេះនូវស្រោមអនាម័យ ចំនួន ១១៥ ២០០ ស្រោម ទឹករំអិល ចំនួន ៤ ០០០ កញ្ចប់ ខិត្តប័ណ្ណផ្សព្វផ្សាយអំពីការការពារ និងធ្វើតេស្ត ឈាមចំនួន ៤៥ ៥០០សន្លឹក អាវយឺត ចំនួន ១ ១៥០ អាវ ថ្នាំបង្ការមុននិងក្រោយពេលប្រឈម (PrEP & PEP) ចំនួន ១០០ឈុត និងតេស្តរកមេរោគអេដស៍ និងកាមរោគ។

## I. ទីតាំងស្តង់អប់រំផ្សព្វផ្សាយ និងធ្វើតេស្តឈាមរកមេរោគអេដស៍នៅតំបន់ទីក្រុងរណបជ្រោយចង្វារ(OCIC)

➢ **សមាសភាពក្រុមការងារ៖**

- ក្រសួងសុខាភិបាល ០២រូប
- មន្ត្រីមជ្ឈមណ្ឌលជាតិចំនួន ៤៣រូប
- ក្រុមការងារ AHF ១០រូប
- ក្រុមការងារ FHI360 ០៣រូប
- ក្រុមការងារ PSI ០៤ រូប
- ក្រុមការងារ KHANA ០៣ រូប
- ក្រុមការងារ MHC ១០ រូប
- ក្រុមការងារ CWPD ១០ រូប
- ក្រុមការងារ Chhouk Sar ០២ រូប
- ក្រុមការងារកម្មវិធីអេដស៍មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ ០៣ រូប




➢ **សកម្មភាព៖**

សម្រាប់ថ្ងៃទី១ នៃយុទ្ធនាការអប់រំផ្សព្វផ្សាយស្តីពីមេរោគអេដស៍ ជំងឺអេដស៍ក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក នាវេលាម៉ោង ២:៣០ នាទី រសៀលជួបជុំអ្នកចូលរួមនៅមុខ

កន្លែងតាំងពិពណ៌នា (Boots) ជិតរង្វង់មូលនាងមច្ឆា អ្នកចូលរួម ១២០ នាក់មកពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ អង្គការដៃគូជាច្រើនដើម្បីត្រៀមលក្ខណៈចូលរួមពិធីហែរដើរក្បួនបើកយុទ្ធនាការផ្សព្វផ្សាយអប់រំយល់ដឹងពីមេរោគអេដស៍ និងជំងឺអេដស៍ក្នុងព្រះរាជពិធីបុណ្យអុំទូកបណ្តែត ប្រទីប និងសំពះព្រះខែ អកអំបុក។

លើសពីនេះទៅទៀតក្រុមការងារបានមានមតិសំណេះសំណាល និងបានធ្វើការអប់រំផ្សព្វផ្សាយស្តីពីមេរោគអេដស៍ ជំងឺអេដស៍ ជំងឺកាមរោគ និងការបង្ការ ផ្សេងៗដោយក្រុមការងារពេលដង្ហែក្បួនទៅកាន់បងប្អូនជាកីឡាករអុំទូក ប្រមាណជាង ៦០០ នាក់ ដែលកំពុងមានវត្តមាន តាមដងផ្លូវ និងនៅតាមកន្លែងស្នាក់នៅ ដោយមានការសម្របសម្រួលពិសេសជាមួយប្រធានក្រុមរបស់កីឡាករអុំទូក ក្នុងការបញ្ជ្រាបការយល់ដឹងស្តីពីការបង្ការមេរោគអេដស៍ និងជំងឺអេដស៍។ ក្នុងនោះផងដែរថ្នាក់ដឹកនាំ និងក្រុមការងារបានធ្វើបទសម្ភាសន៍ជាមួយស្ថានីយ៍ទូរទស្សន៍បាយ័ន(BTV) Fresh news និងក្រុមសារព័ត៌មានបានចុះយកព័ត៌មាននិងចុះផ្សាយនូវសកម្មភាពនៃយុទ្ធនាការនេះផងដែលដើម្បីចូលរួមចំណែកបន្ថែមក្នុងការពង្រីកការផ្សព្វផ្សាយខ្លឹមសារអប់រំ ក្នុងអំឡុងព្រឹត្តិការណ៍នេះ។



វេលាម៉ោង ៤:០០ រសៀល ក្បួនដង្ហែហែរដើរពីកន្លែងតាំងពិពណ៌នាជិតរង្វង់មូលនាងមច្ឆា បើកយុទ្ធនាការផ្សព្វផ្សាយអប់រំយល់ដឹងពីមេរោគអេដស៍ និងជំងឺអេដស៍ក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក តាមដងវិថី OCIC ជាទីដែលកីឡាករអុំទូកមកពី ២៥ រាជធានី-ខេត្ត ស្នាក់នៅ ដើម្បីអប់រំផ្សាយផ្សាយស្វែងយល់ពីមេរោគអេដស៍ ជំងឺអេដស៍ដោយមានការចែកខិត្តប័ណ្ណផ្សព្វផ្សាយអប់រំ និងស្រោមអនាម័យ។

ក្រោយក្បួនដង្ហែចប់ ក្រុមការងារបានបំបែកជាក្រុមតូចៗ ចុះអប់រំដល់កន្លែងកីឡាករអុំទូកស្នាក់នៅ ចែកខិត្តប័ណ្ណអប់រំ ស្រោមអនាម័យ សំនួរចម្លើយពីបញ្ហាអេដស៍ ផ្តល់ការប្រឹក្សាធ្វើតេស្តរកមេរោគអេដស៍-ស្វាយ ដល់អ្នកស្ម័គ្រចិត្តដែលចង់ដឹងពីស្ថានភាពរបស់ខ្លួន។ ក្នុងសកម្មភាពចុះអប់រំផ្សព្វផ្សាយនាពេលនេះ មានការពិតចិត្តនិងចូលរួមពីសំណាក់កីឡាករអុំទូក ប្រជាពលរដ្ឋដែលអញ្ជើញចូលរួមក្នុងក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក យ៉ាងច្រើនកុះករ និងទទួលបានលទ្ធផលជាទីមោទនភាព ក្នុងការចូលរួមបង្ការ ទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីជំរុញឱ្យសម្រេចគោលដៅលុបបំបាត់ការចម្លងមេរោគអេដស៍ថ្មី ស្របតាមគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨។




សកម្មភាពអប់រំផ្សព្វផ្សាយ និងធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក





## សមិទ្ធផលសង្ខេបរួម ថ្ងៃទី១៣ ខែ វិច្ឆិកា ឆ្នាំ ២០២៤

| ល.រ | សកម្មភាព | ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០២៤ | ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០២៤ | ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២៤ | ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០២៤ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | បានអប់រំផ្សព្វផ្សាយ | 11,479 | | | | |
| ២ | បានធ្វើតេស្តឈាម | 12 | | | | |
| ៣ | លទ្ធផលអេដស៍តេស្តប្រតិកម្ម | 00 | | | | |
| ៤ | លទ្ធផលស្វាយតេស្តប្រតិកម្ម | 00 | | | | |
| ៥ | បានចែកស្រោមអនាម័យ | 34,419 | | | | |
| ៦ | បានចែកទឹករំអិល | 1,000 | | | | |
| ៧ | បានចែកខិត្តប័ណ្ណ | 11,479 | | | | |
| ៨ | បានចុះឈ្មោះសេវា PrEP | 01 | | | | |
| ៩ | អាវយឺតសម្រាប់អប់រំ | 600 | | | | |

ថ្ងៃពុធ ១៣ កើត ខែកត្តិក ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០២៤